ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.......សហវ.

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ នៃគ្រួសារមានប័ណ្ណសមធម៌ ឬប័ណ្ណអាទិភាព

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**រដ្ឋមន្ត្រី**
**ក្រសួងសុខាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥/ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/ រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខនស/រកម/ ០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៦១៧/៤៨៨ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសុខាភិបាល
- យោងតាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងក្រសួងសុខាភិបាល



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

## សម្រេច

### ជំពូកទី ១

### បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះ មានគោលបំណងកំណត់ការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកូនអាយុក្រោម ២ឆ្នាំ នៃគ្រួសារដែលមានប័ណ្ណសមធម៌ ឬប័ណ្ណអាទិភាព សំដៅលើកកម្ពស់សុខុមាលភាពមាតា និងទារក ព្រមទាំងរួមចំណែកដោះស្រាយបញ្ហាកង្វះអាហារូបត្ថម្ភរបស់កុមារក្នុងគ្រួសារក្រីក្រ ចាប់តាំងពីកូនក្នុងផ្ទៃរហូតដល់អាយុ ២ឆ្នាំ ដើម្បីជំរុញការលូតលាស់ទាំងកាយសម្បទា និងបញ្ញាស្មារតី។

**ប្រការ ២.-**

ប្រកាសនេះ មានគោលដៅកំណត់អំពីវិធាន នីតិវិធី និងយន្តការគ្រប់គ្រង និងផ្តល់ការឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកូនអាយុក្រោម ២ឆ្នាំក្នុងគ្រួសារដែលមានប័ណ្ណសមធម៌ ឬប័ណ្ណអាទិភាព។

**ប្រការ ៣.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះស្ត្រីមានផ្ទៃពោះ និងកូនអាយុក្រោម ២ឆ្នាំ ក្នុងគ្រួសារដែលមានប័ណ្ណសមធម៌ ឬប័ណ្ណអាទិភាព។

**ប្រការ ៤.-**

វាក្យស័ព្ទបច្ចេកទេស ដែលប្រើនៅក្នុងប្រកាសនេះ មាននិយមន័យដូចខាងក្រោម÷

- ប័ណ្ណសមធម៌ (Pre-ID) សំដៅដល់ប័ណ្ណដែលចេញដោយក្រសួងផែនការដើម្បីកំណត់អត្តសញ្ញាណក្រុមគ្រួសារក្រីក្រ។
- ប័ណ្ណអាទិភាព (Post-ID) សំដៅដល់ប័ណ្ណដែលចេញដោយមន្ទីរពេទ្យសម្រាប់ទទួលសេវាសុខភាពសាធារណៈ និងប័ណ្ណដែលចេញដោយមណ្ឌលសុខភាព សម្រាប់ស្ត្រីក្រីក្រមានផ្ទៃពោះ និងកូនអាយុក្រោម ២ឆ្នាំ។
- ស្ត្រីមានផ្ទៃពោះ សំដៅដល់ស្ត្រីក្នុងគ្រួសារមានប័ណ្ណសមធម៌ ឬប័ណ្ណអាទិភាព ដែលមានផ្ទៃពោះ។

## ជំពូកទី ២
## ស្ថាប័នមានសមត្ថកិច្ចអនុវត្តកម្មវិធី

**ប្រការ ៥.-**

ក្រសួងសុខាភិបាល ត្រូវទទួលបន្ទុកអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកូនអាយុក្រោម ២ឆ្នាំ នៃគ្រួសារមានប័ណ្ណសមធម៌ ឬប័ណ្ណអាទិភាព រហូតដល់មានការកំណត់ជាថ្មីដោយបទប្បញ្ញត្តិដោយឡែក។

## ជំពូកទី ៣
## ប្រាក់ឧបត្ថម្ភជូនស្ត្រីមានផ្ទៃពោះ និងកូនអាយុក្រោម ២ឆ្នាំ

**ប្រការ ៦.-**

ប្រាក់ឧបត្ថម្ភត្រូវបានផ្តល់ជូននៅពេលដែលស្ត្រីមានផ្ទៃពោះ មកទទួលសេវានៅមូលដ្ឋានសុខាភិបាលសាធារណៈ ជាដំណាក់កាល ដូចខាងក្រោម÷

ដំណាក់កាលទី១÷ ផ្តល់ការឧបត្ថម្ភចំនួន ៤០ ០០០ រៀលក្នុង ១ដង សម្រាប់ការមកទទួលសេវាពិនិត្យផ្ទៃពោះ ដែលផ្តល់ជាអតិបរមាចំនួន ៤ដង មុនពេលសម្រាលកូន

ដំណាក់កាលទី២÷ ផ្តល់ការឧបត្ថម្ភចំនួន ២០០ ០០០ រៀល តែ ១ដងគត់ នៅពេលសម្រាលកូន

ដំណាក់កាលទី៣÷ ផ្តល់ការឧបត្ថម្ភចំនួន ៤០ ០០០ រៀលក្នុង ១ដង ដែលផ្តល់ជាអតិបរមាចំនួន ១០ដង ក្នុងនោះ ៣ដង នៅពេលមកទទួលសេវាពិនិត្យសុខភាពក្រោយពេលសម្រាលកូន និង ៧ដង នៅពេលយកកូនមកទទួលថ្នាំបង្ការរហូតដល់អាយុ ២ឆ្នាំ។

ការកំណត់ពេលវេលានៃការទទួលសេវាទាំង ៣ ដំណាក់កាល មាននៅក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ៧.-**

ក្នុងករណីរលូតកូន ប្រាក់ឧបត្ថម្ភនេះត្រូវផ្តល់ជូនដូចខាងក្រោម÷

- ៤០ ០០០ រៀល តែ ១ដងគត់ ក្នុងករណីគភ៌អាយុក្រោម ១២សប្តាហ៍
- ៤០ ០០០ រៀល ក្នុង ១ដង ដែលផ្តល់ជាអតិបរមាចំនួន ២ដង ក្នុងករណីគភ៌អាយុពី ១២សប្តាហ៍ ដល់ ២៤សប្តាហ៍។

ក្នុងករណីកូនស្លាប់ពេលសម្រាល ឬក្រោយពេលសម្រាល ប្រាក់ឧបត្ថម្ភនេះត្រូវបន្តផ្តល់ជូនដូចខាងក្រោម÷

- ២០០ ០០០ រៀល នៅពេលសម្រាល

- ៤០ ០០០ រៀល ក្នុង ១ដង ដែលផ្តល់ជាអតិបរមាចំនួន ៣ដង នៅពេលមកទទួលសេវាពិនិត្យសុខភាពក្រោយពេលសម្រាលកូន។

ក្នុងករណីម្តាយស្លាប់នៅពេលសម្រាល ប្រាក់ឧបត្ថម្ភនេះត្រូវបន្តផ្តល់ជូនអាណាព្យាបាលស្របច្បាប់ ឬអ្នកដែលមានសិទ្ធិស្របច្បាប់ ឬអ្នកដែលនាំកូនមកទទួលសេវា ដូចខាងក្រោម៖

- ២០០ ០០០ រៀល សម្រាប់ការសម្រាល
- ៤០ ០០០ រៀលក្នុង ១ដង ដែលផ្តល់ជាអតិបរមាចំនួន ១០ដង នៅពេលយកកូនមកទទួលសេវាថែទាំសុខភាពរហូតដល់កូនអាយុ ២ឆ្នាំ។

## ជំពូកទី ៤
## ប្រព័ន្ធប្រតិបត្តិការ

**ប្រការ ៨.-**

ក្រសួងសុខាភិបាលត្រូវរៀបចំប្រព័ន្ធប្រតិបត្តិការ ដើម្បីគ្រប់គ្រងការអនុវត្តកម្មវិធីនេះប្រកបដោយប្រសិទ្ធភាព។

ក្រសួងសុខាភិបាលត្រូវជ្រើសរើសធនាគារ ឬគ្រឹះស្ថានហិរញ្ញវត្ថុជាដៃគូដើម្បីអនុវត្តការបើកផ្តល់ប្រាក់ឧបត្ថម្ភ។

**ប្រការ ៩.-**

ក្រសួងសុខាភិបាលត្រូវរៀបចំ និងផ្សព្វផ្សាយសេចក្តីណែនាំសម្រាប់ការអនុវត្តកម្មវិធី រួមមានជាអាទិ៍ការចុះបញ្ជីនិងការផ្ទៀងផ្ទាត់លក្ខខណ្ឌ និងការបញ្ជូនទិន្នន័យទៅធនាគារ ឬគ្រឹះស្ថានហិរញ្ញវត្ថុជាដៃគូដល់គ្រប់មូលដ្ឋានសុខាភិបាលសាធារណៈ។

## ជំពូកទី ៥
## ថវិកាអនុវត្តកម្មវិធី

**ប្រការ ១០.-**

រាល់ការចំណាយលើការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកូនអាយុក្រោម ២ឆ្នាំ នៃគ្រួសារមានប័ណ្ណសមធម៌ ឬប័ណ្ណអាទិភាព ត្រូវហិរញ្ញប្បទានដោយថវិកាជាតិ។

**ប្រការ ១១.-**

ការទូទាត់ចំណាយលើការឧបត្ថម្ភកម្មវិធីនេះ ក្នុង១វដ្តនៃការមានផ្ទៃពោះ រហូតដល់កូនអាយុ ២ឆ្នាំ មិនត្រូវលើសពី ៧៦០ ០០០ រៀល។

## ជំពូកទី ៦

## របាយការណ៍វឌ្ឍនភាព និងរបាយការណ៍ហិរញ្ញវត្ថុ

**ប្រការ ១២.-**

ក្រសួងសុខាភិបាល ត្រូវផ្តល់របាយការណ៍ប្រចាំត្រីមាស និងប្រចាំឆ្នាំអំពីវឌ្ឍនភាពនៃការអនុវត្តកម្មវិធីនេះ ជូនក្រុមប្រឹក្សាជាតិគាំពារសង្គម។ របាយការណ៍ប្រចាំត្រីមាស ត្រូវផ្តល់យ៉ាងយូរក្នុងរយៈពេល ១៥ ថ្ងៃបន្ទាប់ពីដំណាច់ត្រីមាសនីមួយៗ។ របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់យ៉ាងយូរក្នុងរយៈពេល ៣០ ថ្ងៃបន្ទាប់ពីដំណាច់ឆ្នាំនីមួយៗ។

**ប្រការ ១៣.-**

ក្រសួងសុខាភិបាល ត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុស្តីពីការអនុវត្តកម្មវិធី ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន និងត្រូវចម្លងជូនក្រុមប្រឹក្សាជាតិគាំពារសង្គម ក្នុងត្រីមាសទី១ នៃឆ្នាំបន្ទាប់។

ការអនុវត្តកម្មវិធីនេះត្រូវស្ថិតនៅក្រោមអធិការកិច្ច និងសវនកម្មអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី ៧

## កាលបរិច្ឆេទនៃការអនុវត្ត

**ប្រការ ១៤.-**

ការឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកូនអាយុក្រោម ២ឆ្នាំ ដូចមានចែងនៅក្នុងបទប្បញ្ញត្តិនៃប្រកាសនេះ ត្រូវអនុវត្តចាប់ពីថ្ងៃទី១ ខែមិថុនា ឆ្នាំ២០១៩ តទៅ។

**ប្រការ ១៥.-**

ស្ត្រីដែលមានផ្ទៃពោះមុនថ្ងៃទី១ ខែមិថុនា ឆ្នាំ២០១៩ និងកូនអាយុក្រោម ២ឆ្នាំ ដែលបានកើតមុនថ្ងៃទី១ ខែមិថុនា ឆ្នាំ២០១៩ ត្រូវទទួលបានសេវា និងប្រាក់ឧបត្ថម្ភទៅតាមតារាងពេលវេលា ដូចមានកំណត់ក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ សម្រាប់រយៈពេលដែលនៅសល់។

## ជំពូកទី ៨

## អវសានប្បញ្ញត្តិ

**ប្រការ ១៦.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង

សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងក្រសួងសុខាភិបាល ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៧រោច ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៩

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**

**ក្រសួងសុខាភិបាល**

**ម៉ម ប៊ុនហេង**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ ១៦ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

តារាងពេលវេលានៃការផ្តល់សេវា និងប្រាក់ឧបត្ថម្ភជូនស្ត្រីមានផ្ទៃពោះ និងកូនអាយុក្រោម ២ឆ្នាំ

| | សេវាកម្ម | ពេលវេលាទទួលសេវា |
|---|---|---|
| **ដំណាក់កាលទី១** | ការពិនិត្យផ្ទៃពោះលើកទី១ | គភ៌មានអាយុ តិចជាង១២សប្តាហ៍ |
| | ការពិនិត្យផ្ទៃពោះលើកទី២ | គភ៌មានអាយុ ២០ទៅ២៤សប្តាហ៍ |
| | ការពិនិត្យផ្ទៃពោះលើកទី៣ | គភ៌មានអាយុ ៣០ទៅ៣២សប្តាហ៍ |
| | ការពិនិត្យផ្ទៃពោះលើកទី៤ | គភ៌មានអាយុ ៣៦ទៅ៣៨សប្តាហ៍ |
| **ដំណាក់កាលទី២** | ការសម្រាលកូន | តាមកាលវេលាជាក់ស្តែង |
| **ដំណាក់កាលទី៣** | ការពិនិត្យក្រោយសម្រាលលើកទី១ (ពិនិត្យទាំងម្តាយទាំងកូន) | ថ្ងៃទី៧ក្រោយសម្រាល |
| | ការពិនិត្យក្រោយសម្រាលលើកទី២ (ពិនិត្យទាំងម្តាយទាំងកូន) | ថ្ងៃទី១៤ក្រោយសម្រាល |
| | ការពិនិត្យក្រោយសម្រាលលើកទី៣ (ពិនិត្យទាំងម្តាយទាំងកូន) | កូនមានអាយុ១ខែកន្លះ |
| | ការពិនិត្យក្រោយសម្រាលលើកទី៤ (ពិនិត្យសុខភាពកូន) | កូនមានអាយុ២ខែកន្លះ |
| | ការពិនិត្យក្រោយសម្រាលលើកទី៥ (ពិនិត្យសុខភាពកូន) | កូនមានអាយុ៣ខែកន្លះ |
| | ការពិនិត្យក្រោយសម្រាលលើកទី៦ (ពិនិត្យសុខភាពកូន) | កូនមានអាយុ៦ខែ |
| | ការពិនិត្យក្រោយសម្រាលលើកទី៧ (ពិនិត្យសុខភាពកូន) | កូនមានអាយុ៩ខែ |
| | ការពិនិត្យក្រោយសម្រាលលើកទី៨ (ពិនិត្យសុខភាពកូន) | កូនមានអាយុ១២ខែ |
| | ការពិនិត្យក្រោយសម្រាលលើកទី៩ (ពិនិត្យសុខភាពកូន) | កូនមានអាយុ១៨ខែ |
| | ការពិនិត្យក្រោយសម្រាលលើកទី១០ (ពិនិត្យសុខភាពកូន) | កូនមានអាយុ២៤ខែ |